# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៤ សរ-៩៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាគ្រប់ខេត្ត-ក្រុង

**កម្មវត្ថុ:** អំពីការចោទប្រកាន់យោធិនដែលបានប្រព្រឹត្តខុសច្បាប់ ។

ខ្ញុំសូមផ្ញើភ្ជាប់ជាមួយនេះជូនអស់លោកជ្រាប អំពីនីតិវិធីធ្វើការចោទប្រកាន់យោធិន ដែលបានប្រព្រឹត្តខុសច្បាប់នៅក្នុងខេត្ត-ក្រុង មួយចំនួនហើយដែលក្រសួងយុត្តិធម៌បានសុំការសហការពីក្រសួងការពារជាតិ ដើម្បីរួមគ្នារក្សាការពារការគោរពច្បាប់ ការពារសិទ្ធិមនុស្ស និងការពារសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

អំណើះតទៅ បើមានករណីត្រូវចោទប្រកាន់ពីការប្រព្រឹត្តខុសច្បាប់ ការអញ្ជើញយោធិនអោយមកកាន់តុលាការក្នុងវិវាទរដ្ឋប្បវេណី ខ្ញុំសូមអស់លោកសរសេរជាលាយលក្ខ័អក្សរជម្រាបទៅមេបញ្ជាការដែលគ្រប់គ្រងគេនៅក្នុងខេត្ត-ក្រុងនោះបានយល់ដឹងអំពីរឿងហេតុ ហើយសូមឱ្យមេបញ្ជាការនេះបញ្ជូនអ្នកប្រព្រឹត្តខុសច្បាប់មកតុលាការ ឬក៏ឱ្យចូលមកបំភ្លឺតុលាការក្នុងរឿងវិវាទរដ្ឋប្បវេណី។ បើមានការរឹងរូសពីសាមីខ្លួនសូមអស់លោកធ្វើអន្តរាគមន៍ជាលាយលក្ខ័អក្សរទៅមេបញ្ជការ ។

បើមានការរាំងស្ទះពីសំណាក់មេបញ្ជាការវិញ សូមអស់លោកសរសេររាយការណ៍ទៅក្រសួងយុត្តិធម៌ជាបន្ទាន់ ដើម្បីក្រសួងស្រាយបញ្ហានោះជាមួយក្រសួងការពារជាតិ ។

ខ្ញុំសូមអស់លោកមានហើយរក្សាទំនាក់ទំនងសាមគ្គីភាពអោយបានល្អហើយជាប់ជានិច្ច ជាមួយអាជ្ញាធរស៊ីវិល និងយោធានៅខេត្ត-ក្រុង ដែលអស់លោកបំពេញភារកិច្ច ។ សាមគ្គីភាពល្អ ហើយជិតស្និតនឹងជួយជំរុញការងារឱ្យទទួលលទ្ធផលចម្រើនជឿនលឿនទៅមុខសម្រាប់សង្គមជាតិយើង។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការពារជាតិ